មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# ជីវប្រវត្តិលោក លូត សាំង
## អ្នកការពារសិទ្ធិមនុស្ស



*ខ្ញុំមានសុទិដ្ឋិនិយមថានឹងមានតំណាងរាស្ត្រជាជនជាតិដើមភាគតិចនៅក្នុងរដ្ឋសភាជាតិនៅថ្ងៃអនាគត”*

លោក លូត សាំង ជាជនជាតិដើមភាគតិចគួយ កើតនៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៨៧ នៅភូមិស្រែព្រៀង ឃុំប្រមេរ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ។ ម្តាយរបស់លោកគឺជាស្ត្រីមេម៉ាយ មានវ័យ ៤៥ឆ្នាំ ហើយលោកមានបងប្អូនប្រុសស្រី ចំនួន ៦ នាក់។ លោកសាំង បានប្រលងជាប់សញ្ញាបត្រទុតិយភូមិ (បាក់ឌុប) នៅឆ្នាំ២០០៨។ លោកមានបំណងប្រាថ្នាក្លាយជាគ្រូបង្រៀន ឬគ្រូពេទ្យម្នាក់ ប៉ុន្តែលោកពុំបានប្រឡងជាប់ ហើយ លោកក៏បន្តការសិក្សាថ្នាក់ឧត្តមសិក្សានៅសាកលវិទ្យាល័យបៀលប្រាយក្នុងខេត្តសៀមរាប។ ដោយសារជីវភាពខ្វះខាត លោកបានសម្រេចចិត្តឈប់រៀននៅឆ្នាំ២០០៩ ហើយស្វែងរកការងារធ្វើដើម្បីសម្រាលបន្ទុកគ្រួសារ ក្រោយពេលលោកសាំងបានការងារធ្វើហើយនោះ នៅឆ្នាំ២០១៣ លោកបានបន្តការសិក្សានៅវិទ្យាស្ថានក្រុងអង្គរស្ថិតក្នុងខេត្តកំពង់ធំ។ បច្ចុប្បន្នលោកកំពុងសិក្សានីតិសាស្ត្រឆ្នាំទី៣។

នៅឆ្នាំ២០១០ លោកបានដាក់ពាក្យធ្វើការស្ម័គ្រចិត្តនៅអង្គការពន្លកខ្មែរ ហើយត្រូវបានជ្រើសរើសឲ្យធ្វើការនៅអង្គការនេះលើគម្រោងទឹកឃ្មុំ និងអាជីវកម្មរបស់ជនជាតិដើមភាគតិច។ លោកបានបម្រើការងារជាអ្នកស្ម័គ្រចិត្តរយៈពេលប្រាំមួយខែ ក៏ត្រូវជ្រើសរើសចូលជាបុគ្គលិកនៅចុងឆ្នាំ២០១០ ដែលមានតួនាទី មន្ត្រីសម្របសម្រួលសហគមន៍ទទួលបន្ទុកលើគម្រោងជនជាតិដើមភាគតិចក្នុងការចុះបញ្ជីដី និងការចងក្រងសហគមន៍។ ក្នុងតួនាទីជាបុគ្គលិកធ្វើការជាមួយជនជាតិដើមភាគតិច លោក សាំង បានរៀបចំវគ្គបណ្តុះបណ្តាលទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិជនជាតិដើមភាគតិចក្នុងការធ្វើការសម្រេចចិត្តការពារព្រៃឈើ និងដីធ្លីរបស់ពួកគាត់ ព្រមទាំងការតស៊ូមតិដោយសន្តិវិធី ព្រមទាំងចូលរួមឃ្លាំមើលការរំលោភសិទ្ធិមនុស្សនានាដែលកើតមាននៅក្នុងខេត្តព្រះវិហារផងដែរ។

ចាប់តាំងពីលោកចូលបម្រើការងារនៅអង្គការពន្លកខ្មែរ លោកជួបបញ្ហាប្រឈមមួយចំនួនដូចជាការគំរាមកំហែងតាមប្រព័ន្ធតុលាការ ហើយអង្គការពន្លកខ្មែរត្រូវប្រឈមនឹងការបិទជាដើម ដោយសារតែសកម្មភាពលើកកម្ពស់សិទ្ធិមនុស្ស។

ជាក់ស្តែង ក្នុងនាមជាបុគ្គលិកអង្គការសង្គមស៊ីវិលផ្នែកសិទ្ធិមនុស្ស លោក លូត សាំង បានតាមឃ្លាំមើល និងថតរូបផ្តិតយកព្រឹត្តិការណ៍ សហគមន៍ជនជាតិដើមភាគតិចក្នុងឃុំប្រមេរបានបោះជំរុំនៅក្បែរទីស្នាក់ការក្រុមហ៊ុនឡានហ្វេងរយៈពេលបីខែ ចាប់ពីខែមករា ឆ្នាំ២០១៤ ដើម្បីទប់ស្កាត់មិនឲ្យមានការឈូសឆាយដីសហគមន៍ដែលបម្រុងចុះបញ្ជីដីសមូហភាពសម្រាប់សគមន៍ជនជាតិគួយក្នុងឃុំប្រមេរ។ នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១៤ សហគមន៍បានលើកគ្នាទៅដកអំពៅដែលក្រុមហ៊ុនបានភ្ជួរ និងដាំលើដីស្រែដែលមានស្រូវរបស់ពលរដ្ឋ។ នៅពេលនោះលោក សាំង បានចូលរួមឃ្លាំមើល និងថតរូបភាពព្រឹត្តិការណ៍នោះ តែលោកត្រូវរងការចោទប្រកាន់ថាជាអ្នកញុះញង់សហគមន៍ឲ្យទៅបោះជំរុំ។ ស្នងការនគរបាលខេត្តព្រះវិហារបានចេញដីកាកោះឲ្យលោកចូលខ្លួនបំភ្លឺនៅថ្ងៃទី២ និងទី៤ ខែមេសា ឆ្នាំ២០១៤ នៅស្នងការដ្ឋាននគរបាល ប៉ុន្តែការសាកសួរទាំងពីរលើកនេះត្រូវបានលើកពេលដោយសារមានការគាំទ្រតវ៉ាពីពលរដ្ឋ។ នៅថ្ងៃទី៤ ខែមេសាដដែល ព្រះរាជអាជ្ញាសាលាដំបូងខេត្តព្រះវិហារបានចេញដីកាចោទប្រកាន់លោក សាំង ពីបទ "បំផ្លិចបំផ្លាញយ៉ាងឃោរឃៅធ្វើឲ្យខូចខាតអំពៅដោយចេតនា" ទៅតាមពាក្យបណ្តឹងលោក **ជិន ហ្វុង** តំណាងក្រុមហ៊ុន ឡាន ហ្វេង ខេមបូឌា អ៊ីនធឺណេសិនណល លីមីតធីត ដែលចោទថាលោក សាំង បានញុះញង់ឲ្យប្រជាពលរដ្ឋទៅដកអំពៅក្រុមហ៊ុន។ ទោះជាយ៉ាងនេះក៏ដោយ រឿងក្តីរបស់លោកត្រូវ លោក ឡុង ស៊ីថា តំណាងអយ្យការអមសាលាដំបូងខេត្តព្រះវិហារចេញដីកាសម្រេច តម្កល់សំណុំរឿងទុកឥតចាត់ការនៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៤ ដោយមិនបានបញ្ជាក់ពីមូលហេតុឡើយ។

លើសពីសំណុំរឿងនៅតុលាការ នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១៤ លោក អ៊ុំ ម៉ារ៉ា អភិបាលខេត្តព្រះវិហារបានសរសេរលិខិតមួយច្បាប់ផ្ញើជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃសុំឲ្យបិទទីស្នាក់ការអង្គការពន្លកខ្មែរដោយលើកយកមូលហេតុថា អង្គការពន្លកខ្មែរតែងតែញុះញង់ឲ្យប្រជាពលរដ្ឋធ្វើសកម្មភាពខុសច្បាប់ និងផ្ទុយពីលក្ខន្តិកៈរបស់ខ្លួន។ ទោះជាយ៉ាងនេះក្តីអង្គការនេះនៅតែបន្តសកម្មភាពរបស់ខ្លួនធម្មតាដោយមិនមានការរំខានឡើយ។

ក្រៅពីការគំរាមកំហែងតាមប្រព័ន្ធតុលាការ និងផ្លូវរដ្ឋបាល លោក លូត សាំង ក៏ធ្លាប់រងការគំរាមកំហែងដល់អាយុជីវិតទៀតផង។ នៅពេលលោកចុះទៅឃ្លាំមើល និងថតរូបសកម្មភាពឈូសឆាយរបស់ក្រុមហ៊ុន ហើយត្រូវបានក្រុមហ៊ុនគំរាមសម្លាប់ប្រសិនបើលោកធ្វើការផ្សព្វផ្សាយរូបទាំងនោះ។ ដោយសារតែបញ្ហាប្រឈមអាចធ្វើឲ្យប៉ះពាល់សុវត្ថិភាពពីការចាប់ខ្លួន និងសម្លាប់តាមអំពើចិត្ត ក្រុមគ្រួសាររបស់លោកបានសុំឲ្យលោកឈប់ពីការងារមួយនេះ ប៉ុន្តែភាពអយុត្តិធម៌សង្គមបានជំរុញទឹកចិត្តឲ្យលោកបន្តការងារនេះទោះបីជាមានឧបសគ្គក៏ដោយហើយលោកសប្បាយចិត្តនឹងធ្វើវាជានិច្ច។

លោកមានក្តីសង្ឃឹមមុតមាំថារដ្ឋាភិបាលនឹងយកចិត្តទុកដាក់លើជនជាតិដើមភាគតិច ព្រមទាំងផ្តល់សិទ្ធិសេរីភាពគ្រប់គ្រាន់ដល់ពួកគាត់ ជាពិសេសទៅទៀតលោកចង់ឲ្យជនជាតិដើមភាគតិចបានសិក្សាដល់ថ្នាក់ឧត្តមសិក្សាដូចពលរដ្ឋដទៃទៀតដែរ ហើយលោកមានសង្ឃឹមថាជនជាតិដើមភាគតិចនឹងមានសំឡេងនៅក្នុងរដ្ឋសភា។

ចប់